# អារម្ភកថា

*ព្រះសម្មាសម្ពុទ្ធបរមគ្រូ នៃមនុស្សទេវតាទាំងឡាយ ទ្រង់មានព្រះបន្ទូលថា "សេចក្ដីលោភលន់ រមែងអន្តរាយដល់ធម៌ទាំងពួង"។ ទ្រង់មានព្រះបន្ទូលដូច្នេះ គឺទ្រង់ចង់ឲ្យមនុស្សមានការរីកចម្រើនតាមធម្មវិធី គឺត្រូវចេះច្នៃជីវិតរបស់ខ្លួនទៅតាមគន្លងធម៌ ។ ដើម្បីឲ្យបរិស័ទទាំងឡាយមានការរីកចម្រើនទាំងផ្លូវកាយ វាចា ចិត្ត, ទ្រង់មានព្រះបន្ទូលទៀតថា "បព្វជិត គឺអ្នកបួសគ្រប់រូប ត្រូវតាំងនៅក្នុងសីល សមាធិ បញ្ញា រីឯឃរាវាសត្រូវតាំងនៅក្នុងទាន សីល ភាវនា" ។ ទាំងអស់នេះជាអាវុធដ៏វិសេសវិសាល សម្រាប់ច្បាំងជាមួយសត្រូវផ្ទៃក្នុង គឺ "លោភៈ ទោសៈ មោហៈ" ដែលជាមេអកុសលដ៏ធំមហិមា ជាមហាសត្រូវដែលយើងត្រូវតែកំចាត់ដោយធម្មវិធី ។*

*ដើម្បីបំពេញបំណងអស់លោក ដែលធ្លាប់បានអានសៀវភៅ "**ព្រះពោធិសត្វប្រាំរយជាតិ**" ដែលខ្ញុំកូរណាអាត្មាបានសរសេរចប់ជាច្រើនរយរឿងហើយនោះ អង្វរសុំឲ្យសរសេរសៀវភៅប្រភេទនេះផង និងដោយយល់ឃើញថាៈ ការផ្សព្វផ្សាយព្រះធម៌តាមរយៈសៀវភៅ វានឹងមានប្រយោជន៍ខ្លះដល់សង្គមជាតិផង ខ្ញុំកូរណាអាត្មាក៏សម្រេចចិត្តសរសេរសៀវភៅនេះឡើង ហើយដាក់ឈ្មោះថា "**ធម្មជីវិត**"។ ការពិតវាគ្រាន់តែជាកូនសៀវភៅថ្វាយបង្គំព្រះសង្ខេបបែបថ្មីប៉ុណ្ណោះ ហេតុដែលខ្ញុំកូរណាអាត្មាឲ្យឈ្មោះដូច្នេះ ក៏ព្រោះតែយល់ឃើញថាៈ ជីវិតមនុស្សគ្រប់រូប ត្រូវតែអាស្រ័យព្រះធម៌ ទើបរីកចម្រើន មានន័យថាៈ*

(២)

*ពួកគេត្រូវតែជាអ្នកមិនកំណាញ់ស្វិត គឺត្រូវមានចិត្តទូលំទូលាយ (ទាន) មានចិត្តល្អ ស្លូតបូតសុភាពរាបសា (សីល) មានសតិសម្បជញ្ញ (សមាធិ) ទើបរីកចម្រើន ព្រោះព្រះធម៌មិនអាចជួយមនុស្សខិលខូច កោងកាច ខ្ជិលច្រអូស ដេកចាំតែសំណាងនោះទេ គឺជួយតែជនណាដែលចេះជួយខ្លួនឯងប៉ុណ្ណោះ ដូចមានគាថាធម្មបទមួយកន្លែង ប្រែថា "ជនណារក្សាធម៌ ធម៌នឹងរក្សាជននោះ" ។*

*ការសរសេរសៀវភៅនេះ ខ្ញុំកូរណាអាត្មាបានយកសៀវភៅភាណវរៈ និងគាថាធម្មបទខ្លះមកជាគោល ។ ឯកំណាព្យ "មគ្គអង្គ ៨" ខ្ញុំកូរណាអាត្មាបានមកពីលោកគ្រូនួន* **សុខវ៉ាន** *ខ្លះ តែងខ្លួនឯងខ្លះ ។ ឯពាក្យបណ្តៅក៏ដូច្នោះដែរ គឺខ្ញុំកូរណាអាត្មាបានពីលោកតាឡូ* **ម៉ាន់** *ខ្លះ ស្តាប់ចាស់ៗ ខ្លះ ប៉ុន្តែភាគច្រើនជាពាក្យធម្មតា ខ្ញុំកូរណាអាត្មាក៏តែងជាកំណាព្យទាំងអស់ រួមជាមួយនឹងកំណាព្យខ្លួនឯងខ្លះ ។ ហេតុនេះប្រសិនបើមានខុសឆ្គងត្រង់កន្លែងណាមួយ សូមព្រះថេរានុត្ថេរ និងអស់លោកអ្នកអានទាំងឡាយ មេត្តាជួយកែលំអរចែកទានដោយសេចក្តីអនុគ្រោះ ខ្ញុំកូរណាអាត្មា សូមអរព្រះគុណ និងអរគុណ ។*

**វត្តចន្ទសុីសុធារាស** 2312 E Spaulding St. LB., CA 90804

*ថ្ងៃទី ១៥ តុលា ព.ស. ២៥៥១ គ.ស. ២០០៧*

**ព្រះមហា ម៉ាសារិន វិសុទ្ធោ បរិញ្ញាបត្រជាន់ខ្ពស់ (M.A)**

**អតីតសាស្ត្រាចារ្យប្រវត្តិវិទ្យា នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត**

**ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

# មាតិកា

| បញ្ជីរឿង | | ទំព័រ |
|---|---|---|
| ១. | បុព្វបទនការថ្វាយបង្គំព្រះ | ១ |
| ២. | ថ្វាយបង្គំព្រះរតនត្រៃ | ៣ |
| ៣. | បូជាគ្រឿងសក្ការៈ | ៤ |
| ៤. | ពុទ្ធរតនប្បណាម | ៤ |
| ៥. | ពុទ្ធានុស្សតិ | ៥ |
| ៦. | ធម្មានុស្សតិ | ៧ |
| ៧. | សង្ឃានុស្សតិ | ៩ |
| ៨. | ត្រៃសរណគមន៍ | ១២ |
| ៩. | សិក្ខាបទ ៥ | ១៣ |
| ១០. | សុំសេចក្តីសុខ សេចក្តីចម្រើន | ១៤ |
| ១១. | ធម្មសង្វេគបច្ចវេក្ខណបាដ្ឋក | ១៥ |
| ១២. | ផ្សាយមេត្តាឲ្យខ្លួនឯង | ២១ |
| ១៣. | ផ្សាយមេត្តាទូទៅ | ២២ |
| ១៤. | អានិសង្សមេត្តា ១១ | ២៤ |
| ១៥. | ផល្លានិសង្សសុចរិត | ២៥ |
| ១៦. | មិត្តអាក្រក់ មិត្តល្អ | ២៦ |
| ១៧. | ពឹងខ្លួនឯង | ២៧ |
| ១៨. | មិនគួរ | ២៨ |

| | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ១៩. | កតញ្ញូតាធម៌ | ៣០ |
| ២០. | ខន្ធ ៥ ជាតួទុក្ខ | ៣៣ |
| ២១. | បុណ្យនាំឲ្យរីករាយ បាបទាំងឡាយនាំកើតទុក្ខ | ៣៤ |
| ២២. | ឈ្នះខ្លួនឯង ឈ្មោះថាឈ្នះរហូត | ៣៧ |
| ២៣. | ទោសគេមើលឃើញធំ ទោសឯងប៉ុនភ្នំមើលមិនឃើញ | ៤០ |
| ២៤. | អដ្ឋង្គិមគ្គ គឺធម៌ដ៏ប្រសើរប្រៀបបាននឹងផ្លូវ ៨ យ៉ាង | ៤២ |
| ២៥. | សីលប្រាំគួរចាំមិនភ្លេច សីលប្រាំជាកិច្ចអ្នកសាងកុសល | ៥០ |
| ២៦. | ពុទ្ធជ័យមង្គល | ៥៤ |
| ២៧. | បុព្វបទមង្គល ៣៨ | ៦០ |
| ២៨. | មង្គល ៣៨ ប្រការ | ៦២ |
| ២៩. | បុព្វបទបរា | ៦៦ |
| ៣០. | បរាភវសូត្រ គឺសូត្រស្ដីអំពីហេតុចម្រើន/វិនាស | ៦៨ |
| ៣១. | ពាក្យបណ្ដៅ | ៧៧ |
| ៣២. | បើមានម្ហូអ្នកនឹងបានសុខ | ៨៣ |
| ៣៣. | ឈ្នះក្រោធដោយខន្តី | ៨៤ |
| ៣៤. | ក្លិនសីលក្លិនផ្កា | ៨៦ |
| ៣៤. | ជនល្អ | ៨៧ |
| ៣៥. | អ្នកស្វែងសុខក្នុងគំនរទុក្ខអ្នកដទៃ ទុក្ខនោះវិលវៃមកអ្នកវិញ | ៨៨ |
| ៣៧. | សុំសីល ៥/បូជាចង្ហាន់-សុំចង្ហាន់ព្រះ/វេរចង្ហាន់ | ៩០ |
| ៣៨. | ពរប្រាំប្រការ | ៩១ |

# បុព្វបទនៃការថ្វាយបង្គំព្រះ

នៅក្នុងលោកនេះ មានសាសនាជាង ១០០០ សាសនា ប៉ុន្តែ សាសនាដែលគេទទួលស្គាល់ថាជាសាសនាប្រចាំពិភពលោកនោះ មាន ៥ គឺសាសនាព្រះពុទ្ធ ១ សាសនាគ្រឹស្ទ ១ សាសនាអ៊ិស្លាម ១ សាសនាហិណ្ឌូ ១ និងសាសនាស៊ិក្ស ១ ។ សាសនាទាំង ៥ នេះ បើនិយាយអំពីបរិស័ទ សាសនាគ្រឹស្ទមានច្រើនជាងគេ គឺជាប់ថ្នាក់លេខ ១ សាសនាអ៊ីស្លាមលេខ ២ សាសនាព្រះពុទ្ធលេខ ៣ សាសនាហិណ្ឌូលេខ ៤ សាសនាស៊ីក្សលេខ ៥ ។ នេះគឺនិយាយអំពីបរិមាណ តែបើនិយាយអំពីគុណភាពវិញ សាសនាព្រះពុទ្ធជាប់លេខ ១ ព្រោះជីវិតរស់នៅរបស់មនុស្សទាំងឡាយសុទ្ធសឹងប្រកបដោយធម៌ នៃអ្នកត្រាស់ដឹង (ពុទ្ធោ) ទាំងអស់ បើទោះជាគេថាព្រះជាម្ចាស់ជាព្រះតែមួយរបស់គេដោយ ក៏ការអនុវត្តរបស់គេស្របតាមធម៌ព្រះពុទ្ធ ដោយមិនដឹងខ្លួន ។ ឧទាហរណ៍ពួកគេស្រឡាញ់ការសិក្សា និងការងារទូទៅ (**ឆន្ទ**) ព្យាយាមរៀនសូត្រ ព្យាយាមធ្វើការ (**វីរិយ**) យកចិត្តទុកដាក់ក្នុងការរៀនសូត្រ ក្នុងការធ្វើការងារនោះ ៗ (**ចិត្ត**) ត្រិះរិះពិចារណាឲ្យយល់នូវមេរៀនទាំងឡាយដែលខ្លួនកំពុងរៀន ឬការងារផ្សេងៗ ដែលខ្លួនកំពុងធ្វើ (**វិមំសា**) ។ ទាំងអស់នេះលោកហៅថា ( **ឥទ្ធិបាទ**) គឺជាពុទ្ធោវាទសុទ្ធសាធ ឥតក្លែងក្លាយបានឡើយ ។

*សាសនាទាំងអស់នោះសុទ្ធតែមានបទសូត្រមន្តដូចគ្នា ខុសតែការសូត្រ ភាគច្រើនពោលសរសើរដល់ព្រះមួយអង្គ លើកលែងតែពុទ្ធបរិស័ទ ពោលសរសើរព្រះរតនត្រៃ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។*

*ការសូត្រមន្តថ្វាយបង្គំព្រះរតនត្រៃនេះ គឺជាការធ្វើសមាធិថ្នាក់កណ្តាល ព្រោះថាបើយើងតាំងចិត្តសូត្រឲ្យបានជាប់លាប់ យ៉ាងតិចឲ្យបានមួយថ្ងៃ ៣ ដង គឺពេលព្រឹក ល្ងាច និងមុនពេលចូលសម្រាន្ត (អ៊ិស្លាមសូត្រ ៥ ដង) ចិត្តរបស់លោកអ្នកនឹងជួបប្រទះនូវភាពត្រជាក់ស្ងប់សុខ មានកម្លាំង មានបញ្ញា បើទោះជាចិត្តធ្លាប់មានគំនុំជាមួយអ្នកណាម្នាក់ ឬចិត្តប្រកបដោយលោភៈ ទោសៈ មោហៈ ឬចិត្តរវើរវាយក៏នឹងស្ងប់ ឬនឹងរលត់ទៅវិញបន្តិចម្តង ៗ ជម្ងឺស្រាល ៗ ក៏នឹងជាសះស្បើយទៅឯង ដោយមិនបាច់ប្រើថ្នាំអ្វីផងក៏សឹងមាន ។ ហេតុនេះសូមលោកអ្នកព្យាយាមសូត្រមន្តថ្វាយបង្គំព្រះរតនត្រៃសង្ខេប ដូចខាងក្រោមនេះ តែមុននឹងសូត្រយើងត្រូវលុតជង្គង់នៅមុខអាសនៈដែលមានព្រះពុទ្ធរូប ឬកន្លែងដែលគួរ ហើយដាក់ផ្កានៅខាងមុខព្រះពុទ្ធរូប (បើមាន) រួចអុចទៀនធូប ឬមិនបាច់ធ្វើអ្វីទាំងអស់ក៏បានដែរ គ្រាន់តែលុតជង្គង់ (ស្ត្រីអង្គុយបត់កញ្ជែប គឺលុតជង្គង់ដែរតែថ្មុងជើង ខ្នងជើងរាបស្មើនឹងកំរាល) នៅក្នុងកន្លែងដ៏សមគួរមួយ ហើយក្រាបថ្វាយបង្គំ ៣ ដង រួចសូត្របាលីសុទ្ធក៏បាន សូត្រប្រែផងក៏បាន បើមានពេល ព្រោះសូត្រប្រែនេះ នឹងធ្វើឲ្យយើងយល់កាន់តែច្បាស់នូវរសព្រះធម៌ ។*

# ថ្វាយបង្គំព្រះរតនត្រៃ

*បាលី:* **អរហំ សម្មា សម្ពុទ្ធោ ភគវា, ពុទ្ធំ ភគវន្តំ អភិវាទេមិ ។**

*(ក្រាបថ្វាយបង្គំម្តង)*

**ស្វាខាតោ ភគវតា ធម្មោ, ធម្មំ នមស្សាមិ ។**

*(ក្រាបថ្វាយបង្គំម្តង)*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ, សង្ឃំ នមាមិ ។**

*(ក្រាបថ្វាយបង្គំម្តង)*

*ប្រែថា:* **អរហំ សម្មា សម្ពុទ្ធោ ភគវា** *ព្រះដ៏មានព្រះភាគជាព្រះអរហន្ត ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង ។*

**ពុទ្ធំ ភគវន្តំ អភិវាទេមិ** *ខ្ញុំព្រះករុណាសូមអភិវាទព្រះដ៏មានព្រះភាគអង្គនោះដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

**ស្វាខាតោ ភគវតា ធម្មោ** *ព្រះធម៌ជាធម៌ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ។*

**ធម្មំ នមស្សាមិ** *ខ្ញុំព្រះករុណាសូមនមស្សការព្រះធម៌ ។*

*(ក្រាបថ្វាយបង្គំម្តង)*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិល្អហើយ ។*

**សង្ឃំ នមាមិ** *ខ្ញុំព្រះករុណាសូមនមស្សការព្រះសង្ឃ ។*

*(ក្រាបថ្វាយបង្គំម្តង)*